# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ

## ក្រោមប្រធានបទ ភាពតានតឹងបានកើតឡើងកាន់តែខ្លាំងឡើងរវាងខ្មែរនិងថៃ បន្ទាប់ពីរាជរដ្ឋាភិបាលខ្មែរអនុញ្ញាតឲ្យលោកថាក់ស៊ិនចូលមកប្រទេសកម្ពុជា ។

**Website: www.hoksavann.org**

ថ្ងៃទី១២ តុលា ២០០៩



បញ្ហាការដណ្តើមទឹកដីនៅជុំវិញប្រាសាទព្រះវិហាររវាងខ្មែរនិងថៃមិនទាន់ដោះស្រាយរួចផង រាជរដ្ឋាភិបាលខ្មែរបានបន្ថែមបញ្ហាកាន់តែធ្ងន់ថែមទៀត ដោយរាជរដ្ឋាភិបាលខ្មែរបានរៀបចំរាជក្រឹត្យថ្វាយព្រះមហាក្សត្រឲ្យចុះហត្ថលេខា នៅថ្ងៃទី២៧ តុលា ២០០៩ ហើយបានចម្លងផ្សាយនៅថ្ងៃទី៤ វិច្ឆិកា ២០០៩ តែងតាំងលោកថាក់ស៊ិន អតីតនាយករដ្ឋមន្ត្រីថៃ ដែលត្រូវធ្លាក់ពីតំណែងក្នុងរដ្ឋប្រហារយោធាមិនបង្ហូរឈាមមួយកាលពីឆ្នាំ២០០៦ ឲ្យធ្វើជាទីប្រឹក្សាផ្ទាល់នាយករដ្ឋមន្ត្រីខ្មែរ និងជាទីប្រឹក្សារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាទទួលបន្ទុកសេដ្ឋកិច្ច ។ លោកថាក់ស៊ិនបានត្រូវតុលាការនៃរាជរដ្ឋាភិបាលថៃបច្ចុប្បន្ន កាត់ទោសឲ្យជាប់គុក២ឆ្នាំក្នុងបទអំពើពុករលួយ ហើយគេកំពុងតាមចាប់យកមកដាក់គុក ។

ទោះបីប្រមុខរាជរដ្ឋាភិបាលខ្មែរយកលេសថាស្រឡាញ់រាប់អានគ្នាក្នុងឋានៈជាមិត្តភក្តិក្តី មានប្រយោជន៍ដល់គ្នាទៅវិញទៅមកដោយរកស៊ីជាមួយគ្នាក្តី ក៏ត្រូវតែគិតថា នាយករដ្ឋមន្ត្រីជានីតិបុគ្គល ជាតំណាងជាតិខ្មែរ ផលវិបាកអាក្រក់នឹងធ្លាក់មកលើប្រជាពលរដ្ឋខ្មែរនៃប្រទេសកម្ពុជាទាំងមូល ព្រោះតែគាំទ្រសត្រូវរបស់ប្រទេសគេ ។ សូមអ្នកនាំពាក្យដែលបានត្រឹមតែហែអើត្រូវគិតថា ទោះបីលោកថាក់ស៊ិនជាអ្នករងគ្រោះដោយផ្លូវនយោបាយក្តី ដោយមានទោសតាមផ្លូវរដ្ឋគេក្តី នេះជារឿងផ្ទៃក្នុងរបស់គេ ហេតុអ្វីបានជាយើងទៅប្រឡាក់ប្រឡូសជាមួយគេ ធ្វើឲ្យខ្មែរមានបញ្ហា ។ យកអាសារគេនាំឲ្យគ្រោះថ្នាក់ខ្លួនឯង ជាអំពើត្រូវតែជៀសវាង ។ ពាក្យខ្មែរថា មិននៅៗយកជ័រញ្ចៀមកញៀតត្រចៀក ។ ពាក្យថាលោកថាក់ស៊ិនជាអ្នករងគ្រោះនយោបាយ គ្មានប្រទេសណានិយាយទេ សូម្បីថាក់ស៊ិនខ្លួនឯងក៏មិនទាន់ពោលជាសាធារណៈ ឬប្តឹងទៅអង្គការសហប្រជាជាតិឲ្យគេជួយដែរ ។ ប្រទេសអង់គ្លេសនិងប្រទេសបារាំងដែលជាមហាប្រទេស គេបិទមិនចេញទិដ្ឋាការឲ្យថាក់ស៊ិនចូលស្រុកគេឡើយ ។ គេមិនយកចិត្តមនុស្សម្នាក់ ឲ្យខូចមិត្តភាពរវាងប្រទេសគេជាមួយថៃឡើយ ។ ដូច្នេះចាត់គេល្ងង់ដូចខ្មែរ ឬឆ្លាតជាងខ្មែរ ? ។ ទោះបីយើងស្អប់អាភីស៊ីតជានាយករដ្ឋមន្ត្រីបច្ចុប្បន្ននេះក្តី ក៏ជាការចាំបាច់ជៀសវាងមិនបាន ត្រូវតែទទួលស្គាល់គេ ព្រោះគេជាតំណាងប្រទេសថៃបច្ចុប្បន្ននេះ ។

សូមខ្មែររៀនប្រវត្តិសាស្ត្រ ថៃគេទាស់ទែងខ្វែងគំនិតគ្នារហូតធ្វើរដ្ឋប្រហារ គេមិនដែលពឹងបរទេសឲ្យជួយកំទេចថៃគ្នាគេឡើយ ។ ផ្ទុយពីអំពើអាក្រក់របស់អ្នកដឹកនាំខ្មែរ កាលណាមានជម្លោះខ្មែរគ្នាឯង តែងតែទៅពឹងបរទេសដូចជាទៅពឹងសៀម ទៅពឹងយួន ឲ្យមកកំទេចខ្មែរគ្នាឯង ។

នៅពេលទទួលបានព្រះរាជក្រឹត្យ ថាក់ស៊ិននិយាយថា ៖ «នេះជាកិត្តិយសមួយសំរាប់ខ្ញុំ ប៉ុន្តែវាមិនមែនជាការរីករាយដូចដែលខ្ញុំសប្បាយចិត្តជួយប្រជាជនថៃ ឲ្យចាកផុតពីភាពក្រីក្រនោះទេ» ។ ពាក្យនេះបញ្ជាក់ថា ថៃទោះបីគេបែកគ្នាមួយពេល ក៏គេតែងតែគិតដល់ប្រជាជននិងប្រទេសគេជានិច្ច ។ សូមខ្មែរប្រយ័ត្នកុំច្រឡំនយោបាយថៃ ។

ភាពតានតឹងបានកើតឡើងហើយ បន្ទាប់ពីថាក់ស៊ិនបានជាន់ដីកម្ពុជាភ្លាម ។ គណៈរដ្ឋមន្ត្រីថៃបានប្រជុំគ្នាសំរេចលុបចោលអនុស្សារណៈយោគយល់គ្នានៅឆ្នាំ២០០១ ស្តីអំពីព្រំដែនសមុទ្រត្រួតស៊ីគ្នា ក្នុងការរុករកប្រេងកាតនិងឧស្ម័នរួមគ្នា ។ ថៃបានដេញពលរដ្ឋខ្មែរដែលទៅរកស៊ីនៅប្រទេសថៃ ឲ្យចេញពីប្រទេសគេជាបន្តបន្ទាប់គ្នា ។ ថៃបានរៀបចំសំណុំឯកសារជូនទៅរាជរដ្ឋាភិបាលខ្មែរ ឲ្យធ្វើបត្យាប័នបញ្ជូនខ្លួនលោកថាក់ស៊ិនទៅប្រទេសខ្លួនដើម្បីដាក់គុក ។ បើខ្មែរមិនព្រមបញ្ជូនទេ គេនឹងរកមធ្យោបាយផ្សេងទៀត មានទាក់ទងប៉ូលិសអន្តរជាតិឲ្យតាមចាប់លោកថាក់ស៊ិនបញ្ជូនទៅប្រទេសគេ ។ តើវាសនានៃកម្មករខ្មែរមានជាង២សែននាក់ ដែលធ្វើការនៅប្រទេសថៃ ទាំងស្របច្បាប់ទាំងមិនស្របច្បាប់មានដំណើរយ៉ាងណា ? ។ តើព្រះសង្ឃសមណសិស្សរាប់រយអង្គ ដែលកំពុងសិក្សានៅប្រទេសថៃ មានវាសនាយ៉ាងណាដែរ ? ។ តើខ្មែរបាត់បង់អ្នកទេសចរដែលចេញមកតាមច្រកប្រទេសថៃ មានចំនួនប៉ុន្មាននាក់ដែរ បើថៃសំរេចបិទច្រកតាមព្រំដែន ? ។ តើខ្មែររកស៊ីតាមព្រំដែនបាត់វិជ្ជាជីវៈប៉ុន្មាននាក់ដែរ ? ។ តើផលិតផលរបស់ខ្មែរ ដែលធ្លាប់ទៅលក់ឲ្យថៃនោះ ត្រូវបាត់បង់មានទំហំប៉ុណ្ណាដែរ ? ។ តើភាពតានតឹង អាចក្លាយជាជម្លោះប្រដាប់អាវុធឬទេ ? ។ បើអាចកើតមាន អ្នករងគ្រោះគឺប្រជាជនខ្មែរ ត្រូវវិនាសទាំងជីវិតមនុស្សនិងសម្បត្តិរបស់ជាតិ នេះមកពីរដ្ឋាភិបាលខ្មែរយកសត្រូវមកដាក់ក្នុងផ្ទះរបស់ខ្លួន ។ ប្រៀបដូចគេតាមចាប់ចោរ ហើយចោរបានរត់គេចខ្លួនមកប្រទេសកម្ពុជា ដែលមានការគាំទ្រពីរដ្ឋាភិបាលខ្មែរ ថែមទាំងតែងតាំងចោរឲ្យមានមុខងារក្នុងប្រទេសកម្ពុជាផង ។ ករណីរបស់លោកថាក់ស៊ិនមួយទៀត តាមពត៌មានថា ព្រឹទ្ធសភាថៃបានប្តឹងពីបទលោកថាក់ស៊ិនបានប្រមាថព្រះចេស្តាព្រះមហាក្សត្រថៃផង ។ តាមដំណឹងមកទៀតថា ក្រុមហ៊ុនថៃមួយដែលទទួលសង់ផ្លូវលេខ៦របស់ប្រទេសកម្ពុជានៅខេត្តបន្ទាយមានជ័យបានដកខ្លួនចេញ ដោយមិនទាន់បានសង់ផ្លូវរួចរាល់ផង ។

ការការពារព្រំប្រទល់ប៉ែកខាងលិចនៃប្រទេសកម្ពុជាដែលជាប់និងប្រទេសថៃ មិនត្រូវភ្លេចព្រំប្រទល់ដែនប៉ែកខាងកើត

ដែលជាប់និងប្រទេសវៀតណាមឡើយ ព្រោះប្រទេសទាំងពីរនេះតាមប្រវត្តិសាស្ត្រ តែងតែរំលោភយកទឹកដីប្រទេសកម្ពុជា ។ ក្នុងពេលថ្មីៗនេះ ព្រះអតីតមហាក្សត្រខ្មែរ ព្រះករុណាសម្តេចនរោត្តម-សីហនុ បានផ្ញើចុតហ្មាយទៅមេដឹកនាំខ្មែរ គឺប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា និងរាជរដ្ឋាភិបាលខ្មែរ បន្ទាប់ពីព្រះអង្គបានទទួលសារលិខិតលោកសម-រង្ស៊ីជាបក្សជំទាស់ដែលបានចោទថា វៀតណាមបានលួចបោះបង្គោលព្រំដែនចូលមកដីស្រែប្រជាពលរដ្ឋខ្មែរ នៅពេលដែលលោកហែកបិនចូលវត្តមួយក្នុងខេត្តស្វាយរៀង ។ ព្រះអតីតព្រះមហាក្សត្រខ្មែរសុំឲ្យមេដឹកនាំខ្មែរទាំងបីពិនិត្យមើលខ្លឹមសារនៃសារលិខិតរបស់លោកសម-រង្ស៊ីនេះ ។ ស្ថាប័នទាំងបីមិនទាន់ឆ្លើយតបនូវព្រះចុតហ្មាយរបស់ព្រះអតីតព្រះមហាក្សត្រខ្មែរនៅឡើយ ។ ផ្ទុយទៅវិញយើងឮដំណឹងថា អភិបាលស្រុកនៃខេត្តស្វាយរៀងបានដាក់ពាក្យប្តឹងលោកសម-រង្ស៊ីពីបទចោទថា លោកសម-រង្ស៊ីបានបំផ្លាញសម្បត្តិជាតិ ព្រោះបានដកបង្គោលព្រំដែនធ្វើពីឈើ ដែលវៀតណាមបានបោះចូលក្នុងដីស្រែប្រជាពលរដ្ឋខ្មែរ ។ មិនតែប៉ុណ្ណោះ បានផ្លាស់អាចារ្យវត្តដែលទទួលបុណ្យកឋិនរបស់លោកសម-រង្ស៊ីទៀតផង ។ ពត៌មានមួយទៀតថា មានយុវជនខ្មែរជាង១០នាក់នៅភ្នំពេញ បានទៅពិនិត្យមើលបង្គោលព្រំដែននៅខេត្តជាប់និងវៀតណាម តែត្រូវអាជ្ញាធរខ្មែររារាំងមិនឲ្យទៅជិតបង្គោលឡើយ ឲ្យនៅចម្ងាយ១០០ម៉ែត្រ ។ ដំណឹងក្រៅផ្លូវការមួយទៀតថា ប្រជាពលរដ្ឋខ្មែរខ្លះបានលក់ដីឲ្យវៀតណាម ។ យើងឆ្ងល់ថា ហេតុអ្វីបានជាអាជ្ញាធរខ្មែរអនុញ្ញាតឲ្យប្រជាពលរដ្ឋលក់ដីឲ្យបរទេស ថែមទាំងធ្វើប្លង់ឲ្យទៀត ? ។ មួយទៀតដីសម្បទានរាប់ម៉ឺនហិកតា បានត្រូវរដ្ឋាភិបាលខ្មែរផ្តល់ឲ្យវៀតណាម ។ នេះជាបញ្ហាមួយទៀតទៅអនាគតចំពោះដីខ្មែរ ។ ពត៌មានទាំងនេះបញ្ជាក់ថា វៀតណាមនៅតែរំលោភយកទឹកដីខ្មែរដូចប្រទេសថៃដែរ ។

បើព្រឹត្តិការណ៍ខ្មែរ-ថៃដើរដល់ថៃបិទព្រំដែនទាំងស្រុង នោះទំនិញចេញចូលក៏ត្រូវបិទ ទំនិញថៃដែលចូលមកប្រទេសកម្ពុជាតម្លៃចំនួន២ពាន់លានដុល្លារ ឯទំនិញខ្មែរដែលចូលទៅប្រទេសថៃមានចំនួនតែ៩០លានដុល្លារប៉ុណ្ណោះក៏ត្រូវបិទ ។ បើព្រឹត្តិការណ៍កើតមានបែបនេះ អ្នកដឹកនាំវៀតណាមមានចិត្តរីករាយណាស់ ព្រោះអ្នកដឹកនាំថៃនិងវៀតណាមតែងតែសម្លឹងមើលគ្នាទៅវិញទៅមក ដណ្តើមឥទ្ធិពលគ្នាទៅលើប្រទេសកម្ពុជា ។ ដូច្នេះបើទំនិញថៃមិននាំចូលមកប្រទេសកម្ពុជាទេ ជាឱកាសល្អរបស់ប្រទេសវៀតណាម គឺទំនិញវៀតណាមអាចនាំចូលមកប្រទេសកម្ពុជាជំនួសទំនិញថៃ ។ ត្រង់ផលប្រយោជន៍នេះ គេពុំមានភស្តុតាងចោទថា រាជរដ្ឋាភិបាលខ្មែរទទួលមេរៀនពីវៀតណាមឡើយ ទោះបីគេសង្ស័យថា នៅឆ្នាំ១៩៨៩ ពេលដែលវៀតណាមសំរេចចិត្តដកទ័ពថយចេញពីប្រទេសកម្ពុជា វៀតណាមបានរៀបចំផែនការជាស្រេច ក្នុងការត្រួតត្រាលើអ្នកដឹកនាំខ្មែរ ជាពិសេសលើគណបក្សប្រជាជនកម្ពុជា ដោយអាចកំបាំងជាបន្តទៅទៀតក៏ដោយ ។

## រូបមន្តដំណោះស្រាយ

ដើម្បីបន្ធូរបន្ថយភាពតានតឹងរវាងខ្មែរនិងថៃ ឬអាចដោះស្រាយរួចជាស្ថាពរ យើងសូមជូនរូបមន្តដូចតទៅនេះ ៖

១- សូមរាជរដ្ឋាភិបាលខ្មែរលុបចោលព្រះរាជក្រឹត្យ ដែលតែងតាំងលោកថាក់ស៊ីនជាទីប្រឹក្សាសេដ្ឋកិច្ច ហើយកុំឲ្យទិដ្ឋាការចូលប្រទេសកម្ពុជាតទៅទៀត ។ ធ្វើដូច្នេះថៃធូរស្រាលផ្លូវចិត្ត ហើយមិនមានបញ្ហាអំពីថៃសុំបញ្ជូនថាក់ស៊ីនទៅប្រទេសថៃឡើយ ។

២- សូមដាក់បញ្ហាថៃចង់បានដីនៅជុំវិញប្រាសាទព្រះវិហារ ទៅអង្គការអន្តរជាតិដូចជាក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ, តុលាការក្រុងឡាអេ, កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសថ្ងៃ២៣តុលា១៩៩១ ។

ចរិតថៃខ្លាចច្បាប់អន្តរជាតិណាស់ ។ បើដោះស្រាយជាទ្វេភាគី ថៃប្រើល្បិចច្រើនណាស់ ដូចជាប្រឌិតផែនទីជាឯកតោភាគីជាដើម ។ ខ្មែរពិតជាឈ្នះថៃ បើខ្មែរប្រើច្បាប់អន្តរជាតិជាអន្តរការី ។ បើប្រើរូបមន្តនេះ ខ្មែរមិនសូវរវល់ច្រើន ទុកពេលកសាងជាតិតទៅទៀត ។៚